ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ការពិនិត្យមើលបញ្ហាប្រឈមនិងសំណើដំណោះស្រាយ

## ១. ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)

### ១.១. ស្ថានភាពបច្ចុប្បន្ននៃការប្រើប្រាស់ប្រព័ន្ធ FMIS

គិតមកទល់នឹងបច្ចុប្បន្ននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តប្រើប្រាស់ប្រព័ន្ធ FMIS រយៈពេល២ឆ្នាំ នៅលើមុខងារ PO, AP , AR និងBA ដែលមានការវិវឌ្ឍយ៉ាងលឿនពីដំណាក់កាលសិក្សាដល់ការអនុវត្ត និងការទាញយករបាយការណ៍។ សម្រាប់ការសិក្សា និងអនុវត្តយើងបានប្រព្រឹត្តទៅយ៉ាងរលូនកន្លងរួចមកហើយ ដំណាក់កាលដែលក្រុមការងារ របស់នាយកដ្ឋានគណនេយ្យកំពុងតែសិក្សានិងចង់បានបន្ថែមនោះគឺការទាញយករបាយការណ៍ពីប្រព័ន្ធយកមកប្រើប្រាស់សម្រាប់វិភាគការចំណាយផ្សេងៗជូនថ្នាក់ដឹកនាំទាន់ពេលវេលា។

### ១.២. បញ្ហាប្រឈមនៃការប្រើប្រាស់ប្រព័ន្ធ FMIS (ទាំងកត្តាបច្ចេកទេស និងសមត្ថភាព)

- អ្នកពាក់ព័ន្ធក្នុងការអនុវត្តប្រព័ន្ធពុំទាន់បានបំពេញតាមភារកិច្ចរបស់ខ្លួនឲ្យបានពេញលេញ
- មិនទាន់អាចទាញយកទម្រង់របាយកាណ៍យកមកប្រើប្រាស់ឲ្យបានស្របនៅឡើយ
- ការណែនាំពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនិងពុំមានលិខិតបទដ្ឋាន អនុវត្តបណ្តើរជួបបញ្ហាដោះស្រាយតាមករណីនីមួយៗ
- ការចុះប្រតិបត្តិការចំណូលថវិកា គឺចុះទៅតាមសលាកបត្រចំណូលរបស់ក្រសួង ពុំអាចបង្ហាញពីស្ថានភាពចំណូលដែលក្រសួងប្រមូលបាន (ប្រាក់រង្វាន់)
- របាយការណ៍ចំណូល (R20) បានបង្ហាញតែចំណូលដែលបានកត់ត្រាចូលថវិកាជាតិ។

### ១.៣. ផែនការជាយុទ្ធសាស្ត្រដើម្បីអនុវត្តប្រព័ន្ធ FMIS ប្រកបដោយប្រសិទ្ធភាព

- ពិនិត្យឡើងវិញលើតួនាទីភារកិច្ចរបស់មន្ត្រីដែលអនុវត្តប្រព័ន្ធ FMIS ឲ្យបានសមស្រប
- ពិនិត្យនិងផ្ទៀងផ្ទាត់ប្រៀបធៀបជាប្រចាំរវាងរបាយការណ៍ដែលប្រព័ន្ធFMIS ផលិតបាន ជាមួយនឹងការកត់ត្រាផ្សេងៗរបស់ក្រសួង
- ត្រៀមខ្លួនចូលរួមសហការជាមួយក្រុមការងារFMIS/MEF។

### ១.៤. សំណើដំណោះស្រាយមកកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ស្នើសុំអ្នកពាក់ព័ន្ធក្នុងការអនុវត្តបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយឆន្ទៈខ្ពស់
- ស្នើអោយក្រុមការងារ FMIS/MEF រៀបចំទម្រង់របាយការណ៍ផ្សេងៗក្នុងប្រព័ន្ធឲ្យដូចក្នុងសារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ដើម្បីអាចឲ្យក្រសួងស្ថាប័នអាចទាញចេញយកមកប្រើប្រាស់បាន
- ស្នើអោយក្រុមការងារ FMIS/MEF ជួយបង្រៀនបន្ថែមពីរបៀបទាញយករបាយការណ៍ពីប្រព័ន្ធរហូតដល់ការវិភាគរបាយការណ៍
- ការចុះប្រតិបត្តិការចំណូលថវិកា គឺចុះទៅតាមចំណូលរបស់ក្រសួងដែលប្រមូលបាន (ផ្នែកថវិកាជាតិ និងប្រាក់រង្វាន់)
- ស្នើសុំបង្កើតក្រុមសម្របសម្រួលកម្រិតខ្ពស់ដែលអាចធ្វើការដោះស្រាយនៅពេលមានបញ្ហាកើតឡើង។

## ៣. ការចាយថវិកាទាបជាងគោលដៅត្រីមាស

### ៣.១. មូលហេតុដែលបណ្តាលឲ្យការចាយថវិកាទាបជាងគោលដៅត្រីមាស

- ការទទួលថវិការជ្ជទេយ្យបុរេប្រទានពីអគ្គនាយកដ្ឋានរតនាគារជាតិនៅមានការយឺតយ៉ាវនៅដើមឆ្នាំ
- ការចំណាយតាមនីតិវិធីលទ្ធកម្មសាធារណៈមិនអាចអនុវត្តទៅតាមផែនការលទ្ធកម្ម ការស្នើសុំធានាចំណាយទៅMEF ពេលខ្លះត្រូវប្រើពេលយូរ នីតិវិធីលទ្ធកម្មក៏ប្រើពេលច្រើន ដែលនាំឲ្យការទូទាត់ចំណាយត្រូវអូសបន្លាយពេលវេលា
- អង្គភាពថវិកានៅមិនទាន់អនុវត្តឲ្យបានតាមផែនការនៅឡើយ
- ការទូទាត់ចំណាយផ្សេងៗទៅMEF ឆ្លងកាត់ដំណាក់កាលច្រើនធ្វើឲ្យបន្លាយការងារដែលត្រូវអនុវត្ត។

### ៣.២. ផែនការជាយុទ្ធសាស្ត្រដើម្បីជំរុញការចាយថវិកាឲ្យតាមគោលដៅត្រីមាស

- នៅឆ្នាំ២០២០ រៀបចំសិក្ខាសាលាបណ្តុះបណ្តាលដោយផ្តោតទៅលើការរៀបចំផែនការចំណាយតាមពេលវេលា ពង្រឹងសមត្ថភាព ពិសេសអ្នករៀបចំផែនការចំណាយទៅតាមអង្គភាពថវិកា
- ចាប់ពីឆ្នាំ២០២១ តម្រូវឲ្យអង្គភាពថវិកានីមួយៗរៀបចំផែនការចំណាយទៅតាមពេលវេលាជាក់លាក់ និងតាមដានការអនុវត្តចំណាយជាក់ស្តែងធៀបនឹងផែនការដែលអង្គភាពថវិកាបានដាក់ចេញ
- ពិនិត្យវាយតម្លៃលើការអនុវត្តចំណាយតាមពេលវេលារបស់អង្គភាពថវិកានីមួយៗ
- ណែនាំជាបណ្តើរៗ និងវិធានការកែលម្អដល់អង្គភាពថវិកា។

### ៣.៣. សំណើដំណោះស្រាយមកកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ពន្លឿនបើកផ្តល់ថវិកាឲ្យបានពីដើមឆ្នាំ
- កាត់បន្ថយនីតិវិធីពិនិត្យចំណាយនៅMEF ឲ្យបានខ្លី
- កាត់បន្ថយលំហូរឯកសារនៅMEF ឲ្យបានលឿន
- បើកវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងការរៀបចំផែនការចំណាយតាមពេលវេលាឲ្យបានច្បាស់លាស់។

ថ្ងៃពុធ ១៣រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ធ្វើនៅភ្នំពេញ,ថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

អ្នករៀបចំអត្ថបទ

គង់ សុធីរ

បានឃើញនិងឯកភាព

ថ្ងៃច័ន្ទ ៣កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០២០

**ប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**